# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តប្រើប្រាស់បុនហិរញ្ញប្បទានអាជីវកម្ម

តាមរយៈការស្នើសុំបុនហិរញ្ញប្បទានអាជីវកម្មអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្ត អតិថិជនយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ("**កម្មវិធីលើកទឹកចិត្ត**") ព្រមទាំងគោលនយោបាយឥណទាន និងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធរបស់ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**")៖

១. រាល់អតិថិជនទាំងអតិថិជនចាស់ និងថ្មី ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល អាចដាក់ពាក្យសុំបុនហិរញ្ញប្បទានអាជីវកម្មពីធនាគារផ្សេងបាន។

២. ក្នុងករណីពាក្យស្នើសុំបុនហិរញ្ញប្បទានអាជីវកម្មរបស់អតិថិជន (ទាំងឥណទានមានកាលកំណត់ និងឥណទានវិបារូបន៍) ត្រូវបានដាក់ក្នុងអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្តនេះ ត្រូវបានអនុម័តយល់ព្រមដោយធនាគារ ព្រីនស៍ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន អតិថិជនអាចទទួលបានការផ្តល់ជូននូវអត្ថប្រយោជន៍ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម៖

<table>
<tr><th>ការផ្តល់ជូន</th><th>រយៈពេលកម្មវិធីលើកទឹកចិត្ត (កាលបរិច្ឆេទដាក់ស្នើសុំ)</th></tr>
<tr><td>- ទំហំបុនហិរញ្ញប្បទាន៖ រហូតដល់ ៥០០.០០០ ដុល្លាអាមេរិក<br>- អត្រាការប្រាក់៖<br><table><tr><th>អតិថិជនទិញធានារ៉ាប់រង LRI *</th><th>អតិថិជនមិនទិញធានារ៉ាប់រង LRI</th></tr><tr><td>- ឆ្នាំទី១៖ ៦% ក្នុងមួយឆ្នាំ<br>- ចាប់ពីឆ្នាំទី២៖ ៧,៩៩%ក្នុងមួយឆ្នាំ<br>- រហូតដល់ ៨០% នៃតម្លៃទ្រព្យ</td><td>- ៧,៩៩%ក្នុងមួយឆ្នាំ<br>- រហូតដល់ ៧០% នៃតម្លៃទ្រព្យ</td></tr></table>- ឥណទានបន្ថែម៖ មិនមានការកំណត់លើការស្នើប្រាក់កម្ចីបន្ថែម ប៉ុន្តែកម្រិតអតិបរមានៃកម្ចីសរុបគឺត្រឹម ៥០០.០០០ដុល្លារ។<br>- កម្រៃសេវាបុនហិរញ្ញប្បទាន៖ លើកលែង<br>- កម្រៃសេវាអនុម័តឥណទាន៖ ត្រឹមតែ១% នៃទំហំឥណទានអនុម័ត</td><td>២៧ មីនា ដល់ ៣១ ធ្នូ ២០២៣</td></tr>
<tr><td colspan="2"><u>លក្ខខណ្ឌ៖</u><br>- រយៈពេលហាមឃាត់ធ្វើការទូទាត់សងឥណទានមុនកំណត់ដោយផ្នែកឬទាំងស្រុង៖ ៥ ឆ្នាំ ឬ អតិថិជនត្រូវបង់ប្រាក់ពិន័យ ៣% នៃចំនួនទឹកប្រាក់ទូទាត់សងមុនកាលកំណត់<br>- ការជូនដំណឹងអំពីការទូទាត់សងមុនកាលកំណត់៖ ១ ខែមុន ឬ អតិថិជនត្រូវបង់ប្រាក់ពិន័យ ១%នៃចំនួនទឹកប្រាក់ទូទាត់សងមុនកាលកំណត់<br>- វិធីទូទាត់សង៖ បង់រំលស់ប្រចាំខែស្មើៗគ្នា បង់រំលស់ប្រាក់ដើមថេរ ឬទូទាត់នៅចុងគ្រា<br>- មិនមានគណនីឥណទានរៀបចំឡើងវិញ ឬ មិនមានគណនីឥណទានយឺតយ៉ាវសម្រាប់រយៈពេល ១២ ខែចុងក្រោយ<br>- ប្រវត្តិនៃការទូទាត់សងល្អមិនមានការយឺតយ៉ាវនៅក្នុង CBC សម្រាប់រយៈពេល ១២ ខែចុងក្រោយ<br>- មិនមានប្រវត្តិនៃការចេញមូលប្បទានបត្រដោយគ្មានសាច់ប្រាក់លើលពី២ដង ក្នុងរយៈពេល១២ខែចុងក្រោយ</td></tr>
</table>

| |
|---|
| - មិនមានប្រវត្តិនៃការទូទាត់សងយឺតយ៉ាវហួតដល់១០ថ្ងៃលើសពី២ដងក្នុងរយៈពេល១២ខែចុងក្រោយ<br>- អតិថិជនថ្មីដែលមានប្រវត្តិទូទាត់សងល្អយ៉ាងហោចណាស់សម្រាប់រយៈពេល ១២ ខែចុងក្រោយ<br>- លក្ខខណ្ឌបន្ថែមសម្រាប់អតិថិជន ទិញធានារ៉ាប់រងLRI៖<br>១. តម្រូវឱ្យអតិថិជនទិញធានារ៉ាប់រងការទូទាត់សងប្រាក់កម្ចី (LRI) ស្មើនឹង ១០០% នៃចំនួនប្រាក់កម្ចី និងដាក់ឈ្មោះ ធនាគារ ព្រីនស៍ ជាអត្ថគាហកតែមួយគត់<br>២. រយៈពេលអប្បបរមាទិញLRI៖ ៥ ឆ្នាំ.<br>៣. អនុញ្ញាតអោយអតិថិជនស្នើសុំបន្ថែមឥណទានដើម្បីទិញធានារ៉ាប់រង LRI ជាមួយកម្ចីដែលបានស្នើសុំ។<br>បញ្ញត្តិ និងលក្ខខណ្ឌនៃសំណុំឯកសារហិរញ្ញប្បទានរបស់ ធនាគារ ព្រីនស៍ ត្រូវអនុវត្ត។ |

* LRI ៖ ធានារ៉ាប់រងលើការទូទាត់សងកម្ចី

៣. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អតិថិជន យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អតិថិជន យល់ព្រមដោយមិនដកវិញថា អតិថិជនយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអតិថិជន ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៤. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអតិថិជនទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អតិថិជនរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ។ ដូច្នេះ អតិថិជនណាដែលបានទទួលអត្ថប្រយោជន៍នៅក្នុងកម្មវិធីលើកទឹកចិត្តនេះ ត្រូវប្រគល់អត្ថប្រយោជន៍ទាំងនោះជូនមកធនាគារ ព្រីនស៍ វិញ ហើយត្រូវសងសំណងការខូចខាតផ្សេងៗមកធនាគារ ព្រីនស៍ទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៥. អតិថិជនយល់ព្រមឲ្យធនាគារ ព្រីនស៍ ធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យារពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬរង្វាន់លើកទឹកចិត្តដែលផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្តដោយមិនមានការទទួលខុសត្រូវ តាមរយៈការជូនដំណឹងពីការផ្លាស់ប្តូរនេះ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលមានរបស់ ធនាគារ ព្រីនស៍។

៦. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ ធនាគារ ព្រីនស៍ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។